# ព្រឹត្តិបត្រប្រចាំត្រីមាសទី១

## គាំទ្រសមាគម គឺពង្រឹងវិស័យទឹកស្អាតនៅកម្ពុជា

សម្រាប់ ខែមករា ដល់ ខែមីនា ឆ្នាំ២០២៦

## ១. បច្ចុប្បន្នភាពអំពីសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយមានស្ថាបនិកចំនួន ២០រូប និងត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីសមាគមតាមរយៈលិខិតលេខ ១០៧៧ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។

ដោយមានភាពរីកចម្រើន ទទួលបានទំនុកចិត្ត និងការគាំទ្រពីប្រតិបត្តិករ ក្រុមហ៊ុន សហគ្រាស និងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា សមាគមបានសម្រេចបញ្ចូលសមាជិកបន្ថែមមានទាំងរូបវន្តបុគ្គល និងនិតិបុគ្គល។ ដូច្នេះហើយទើបក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសលេខ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋានទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២៦ សមាគមមានសមាជិកសរុបចំនួន ៣៣២ ក្នុងនោះមានសមាជិកអាជីពចំនួន ២៨១ ស្ថានីយ ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣ រាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា និងសមាជិកគាំទ្រចំនួន ៥១ ក្រុមហ៊ុន។

## ១.១. បច្ចុប្បន្នភាពសមាជិក

តារាងបច្ចុប្បន្នភាពសមាជិកគិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០២៦៖




*ក្រាហ្វិច១៖ ទិន្នន័យសមាជិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា គិតត្រឹមថ្ងៃទី ៣១ខែមីនា ឆ្នាំ២០២៦*

## ១.២. ការបាត់បង់សមាជិកភាព និងសមាជិកថ្មី

តារាងការបាត់បង់សមាជិកភាព និងសមាជិកថ្មីគិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០២៦៖

| ចំនួនសមាជិក | ស្ថានីយ | ក្រុមហ៊ុន | សរុប |
|---|---|---|---|
| ចំនួនសមាជិកសរុបត្រឹមដំណាច់ឆ្នាំ២០២៥ | ២៨៦ | ៥៧ | ៣៤៣ |
| ចំនួនសមាជិកដែលបានបញ្ចប់សមាជិកភាព | ១៤ | ៧ | ២១ |
| ចំនួនសមាជិកថ្មី | ៧ | ២ | ៩ |
| ចំនួនសមាជិកដែលចូលមកវិញ | ២ | | |
| ចំនួនសមាជិកដែលប្តូរសមាជិកភាព | | ១ | ១ |
| ចំនួនសមាជិកសរុបត្រឹម ខែមីនា ឆ្នាំ២០២៦ | ២៨១ | ៥១ | ៣៣២ |

## ២. ការងារស្នូលសមាគម

### ២.១. កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៥ និងលើកផែនការឆ្នាំ២០២៦

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦ សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៥ និងលើកផែនការឆ្នាំ២០២៦ នៅការិយាល័យសមាគម ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមសរុបចំនួន ១៨ នាក់ (ស្រី ៦នាក់)។

គោលបំណង៖

១. បង្ហាញពីសមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងមេរៀនបទពិសោធន៍ល្អៗពីការអនុវត្តការងារឆ្នាំ ២០២៥
២. បង្ហាញទិសដៅការងារឆ្នាំ២០២៦
៣. ពន្យល់ពីលក្ខន្តិកៈ និងគោលនយោបាយរបស់សមាគម
៤. បង្កើនភាពស្និទ្ធស្នាល និងទំនាក់ទំនងល្អរវាងគ្នានឹងគ្នា។

ជាលទ្ធផល អង្គប្រជុំបានពិភាក្សាយ៉ាងផុលផុសលើរបៀបវារៈដែលបានលើកមកបង្ហាញ និងបានឯកភាពលើផែនការសម្រាប់ឆ្នាំ២០២៦ដូចខាងក្រោម៖













### ២.២. សន្និបាតលើកទី១៤

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំសន្និបាតលើកទី១៤ ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦។

គោលបំណង៖

១. អបអរសាទរសមិទ្ធិផលរបស់សមាគមឆ្នាំ២០២៥ និងលើកផែនការការងារប្រចាំឆ្នាំ២០២៦

២. ប្រកាសសមាសភាពគណៈកម្មាធិការទាំង៤ (ស្វែងរកការគាំទ្រមតិ សេវាកម្មសមាជិក ហិរញ្ញវត្ថុ និង អភិវឌ្ឍន៍ បណ្តុះបណ្តាល) និងការអនុវត្តមូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត (ម.អ.ស.វ)
៣. ចែករំលែកបទពិសោធន៍ការអនុវត្តល្អ អត្ថប្រយោជន៍នៃការចូលជាសមាជិកសមាគម ស្តាប់សំឡេងរបស់សមាជិក និងរួមគ្នាស្វែងរកដំណោះស្រាយ
៤. បង្កើនទំនាក់ទំនងជាមួយសមាជិកឱ្យកាន់តែប្រសើរឡើង និងទស្សនាពិព័រណ៍បច្ចេកវិទ្យាថ្មីៗ

**ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ជាប្រធានគណៈអធិបតីក្នុងកម្មវិធីបើកសន្និបាតលើកទី១៤ របស់សមាគម។ សន្និបាតលើកទី១៤ មានការអញ្ជើញចូលរួមពីក្រសួងពាក់ព័ន្ធ ដូចជា៖ ក្រសួងឧ.វ.ប.ន. ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ សហភាពអឺរ៉ុប ស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អង្គការដៃគូដូចជា៖ កម្មវិធី CAPRED អង្គការ Water.org អង្គការ WaterAid ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម សមាជិកអាជីព និងសមាជិកគាំទ្រ សរុបចំនួន ៤១២ នាក់ (ស្រី ១២៣ នាក់) ក្នុងនោះមានសមាជិកអាជីពចំនួន ១៦៩ ស្ថានីយ សមាជិកគាំទ្រចំនួន ៣៧ ក្រុមហ៊ុន។



*រូបភាពទី 1៖ សន្និបាតលើកទី១៤*

អង្គសន្និបាតទទួលបានកិច្ចសហការឧបត្ថម្ភគាំទ្រពីសមាជិកសមាគម និងដៃគូសរុបចំនួន ៣៣ ស្ថានប័នដូចខាងក្រោម៖




*រូបភាពទី 2៖ ដៃគូសហការ និងឧបត្ថម្ភសន្និបាតលើកទី១៤*

## ២.៣. ការសម្រុះសម្រួលវិវាទ

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ សមាគមបានដឹកនាំសមាជិកចំនួន ១៥ នាក់ ចូលរួមកិច្ចប្រជុំដោះស្រាយវិវាទរវាងស្ថានីយផ្គត់ផ្គង់ទឹកស្អាតពោធិបាន និងអតិថិជន នៅសាលាឃុំពោធិបាន។ កិច្ចប្រជុំនេះផ្តោតលើបញ្ហាការយកទឹកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ស្ថានីយ។ កិច្ចប្រជុំនេះដឹកនាំដោយ លោកមេឃុំពោធិបាន ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំពោធិបាន ភាគីវិវាទទាំងសងខាង សមាគម និងសមាជិក។

កិច្ចប្រជុំនេះមិនទទួលបានលទ្ធផលទេ ព្រោះភាគីអតិថិជនមិនព្រមទទួលស្គាល់ថា បានយកទឹកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ស្ថានីយ។ ក្នុងករណីនេះ សមាគមនឹងបន្តគាំទ្រសមាជិករបស់ខ្លួនដើម្បីបន្តនីតិវិធី។



*រូបភាពទី 3៖ ការសម្រុះសម្រួលវិវាទរវាងប្រតិបត្តិករ និងអតិថិជន*

## ២.៣. ការងាររបស់គណៈកម្មាធិការទាំង៤

### ២.៣.១ កិច្ចប្រជុំគណៈកម្មាធិការទាំង៤

ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ សមាគមបានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយគណៈកម្មាធិការទាំង៤ គឺ ១) គណៈកម្មាធិការស្វែងរកការគាំទ្រមតិ ២) គណៈកម្មាធិការសេវាកម្មសមាជិក ៣) គណៈកម្មាធិការហិរញ្ញវត្ថុ និង ៤) គណៈកម្មាធិការអភិវឌ្ឍន៍បណ្តុះបណ្តាល។ កិច្ចប្រជុំបានប្រារព្ធឡើងដោយមានអ្នកចូលរួមសរុបចំនួន ២៤ នាក់ (ស្រី ៧ នាក់) ដើម្បីណែនាំឱ្យបានស្គាល់គ្នារវាងសមាជិក និងថ្នាក់ដឹកនាំគណៈកម្មាធិការ ព្រមទាំងបង្ហាញពីគោលបំណងនៃការបង្កើតគណៈកម្មាធិការទាំង៤ និងសកម្មភាពចម្បងៗ។ កិច្ចប្រជុំបានបញ្ចប់ទៅដោយស្មារតីភាតរភាពក្រៃលែង។




*រូបភាពទី ៤៖ កិច្ចប្រជុំគណៈកម្មាធិការទាំង៤*

### ២.៣.២ កិច្ចប្រជុំរបស់គណៈកម្មាធិការស្វែងរកការគាំទ្រមតិ

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ គណៈកម្មាធិការស្វែងរកការគាំទ្រមតិ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Call) ដើម្បីដោះស្រាយបញ្ហាខ្វះខាតប្រភពទឹកសម្រាប់ផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជនប្រើប្រាស់ប្រចាំថ្ងៃរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សុត សឿន ដែលមានទីតាំងស្ថិតនៅឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់។ កិច្ចប្រជុំមានគោលបំណង៖

១. ស្វែងយល់ពីបញ្ហាដែលបានកើតមានឡើងនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត សុត សឿន
២. ស្វែងរកដំណោះស្រាយអំពីបញ្ហាដែលបានកើតមានឡើង
៣. កំណត់ពេលវេលា និងសកម្មភាពចម្បងៗដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហា។

គណៈកម្មាធិការ បានផ្តល់អនុសាសន៍ម្ចាស់ស្ថានីយដាក់លិខិតទៅមន្ទីរធនធានទឹក និងឧតុនិយមតាមរយៈមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីស្នើសុំប្រើប្រភពទឹករណ្តៅខ្សាច់ក្នុងអូរ ដែលមានប្រភពទឹកមកពីប្រឡាយមេដំណាក់អំពិល ដើម្បីយកមកផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជនប្រើប្រាស់។




*រូបភាពទី ៥៖ កិច្ចប្រជុំរបស់គណៈកម្មាធិការស្វែងរកការគាំទ្រមតិ*

### ២.៣.៣ កិច្ចប្រជុំរបស់គណៈកម្មាធិការអភិវឌ្ឍន៍បណ្តុះបណ្តាល

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ គណៈកម្មាធិការអភិវឌ្ឍន៍បណ្តុះបណ្តាល បានជួបប្រជុំជាលើកដំបូងតាមប្រព័ន្ធអនឡាញ (Zoom Call) ដើម្បីពិភាក្សាអំពីតួនាទី និងភារកិច្ច និងការស្ទង់មតិអំពីតម្រូវការបណ្តុះបណ្តាល របស់សមាជិកដែលជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ ការស្ទង់មតិនេះមានគោលបំណងដើម្បីគាំទ្រ និងកសាងសមត្ថភាពរបស់សមាជិកឱ្យក្លាយជាអ្នកផ្គត់ផ្គង់សេវាទឹកស្អាតអាជីពនាពេលខាងមុខ។ ជាលទ្ធផល សមាជិកគណៈកម្មាធិការទាំងអស់បានយល់កាន់តែច្បាស់អំពីតួនាទី និងភារកិច្ច និងបានព្រមព្រៀងក្នុងការអនុវត្តការស្ទង់មតិអំពីតម្រូវការបណ្តុះបណ្តាលរបស់សមាជិកដែលជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។




*រូបភាពទី ៦៖ កិច្ចប្រជុំរបស់គណៈកម្មាធិការអភិវឌ្ឍន៍ បណ្តុះបណ្តាលលើកទី១*

## ២.៤. ដំណើរទស្សនកិច្ចសិក្សាក្នុងប្រទេស

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ សមាគមបានដឹកនាំសមាជិកចំនួន ៣០ នាក់ (ស្រី ៥ នាក់) ទៅទស្សនកិច្ចសិក្សាស្វែងយល់អំពីការគ្រប់គ្រងអាជីវកម្ម បច្ចេកទេសផលិតទឹកស្អាត ការរៀបចំប្រព័ន្ធម៉ូទ័រ និងការរៀបចំបន្ទប់ពិសោធន៍នៅរដ្ឋាករទឹកពោធិ៍សាត់។ ទស្សនកិច្ចនេះមានគោលបំណងផ្តល់ចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងដើម្បីឱ្យសមាជិកអាចយកទៅអភិវឌ្ឍ និងពង្រឹងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។



*រូបភាពទី 7៖ ដំណើរទស្សនកិច្ចសិក្សាទៅកាន់ រដ្ឋាករទឹកពោធិ៍សាត់*

សមាគមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គនាយក** និងសហការីរដ្ឋាករទឹកពោធិ៍សាត់ ដែលបានរៀបចំស្វាគមន៍ និងទទួលគណៈប្រតិភូរបស់សមាគមយ៉ាងកក់ក្តៅ។ ជាពិសេសមន្ត្រីបច្ចេកទេសរដ្ឋាករទឹក បានណែនាំ និងបង្ហាញយ៉ាងលម្អិតអំពីចង្វាក់ផលិតកម្មទឹកស្អាត ប្រព័ន្ធទូបញ្ជាម៉ូទ័រ ព្រមទាំងបន្ទប់ពិសោធន៍ និងឧបករណ៍តេស្តនានា ដែលអាចឱ្យប្រតិបត្តិករយល់ដឹងបានច្បាស់លាស់ និងអាចយកទៅអនុវត្តបានជាក់ស្តែង។



*រូបភាពទី ៨៖ ជំនួបជាមួយ ឯកឧត្តមអគ្គនាយក និងសហការីរដ្ឋាករទឹកពោធិ៍សាត់*

## ២.៦. វគ្គបណ្តុះបណ្តាល

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០**» នៅសណ្ឋាគារសាន់វេ ភ្នំពេញ។ វគ្គបណ្តុះបណ្តាលមានអ្នកចូលរួមសរុបចំនួន ៣០ នាក់ (ស្រី ១០ នាក់) ដែលអញ្ជើញមកពី ២១ ស្ថានីយ និង ២ ក្រុមហ៊ុន។ ជាលទ្ធផលអ្នកចូលរួមអាចរៀបរាប់បានពី ១) ទិន្នន័យ ដើម្បីយកមកគណនាតម្រូវការទឹកស្អាត ២) សមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបច្ចុប្បន្ន និងសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលត្រូវការបន្ថែម និង ៣) ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ ២០២៦-២០៣០ សម្រាប់ស្ថានីយរបស់ខ្លួន។




*រូបភាពទី ៩៖ វគ្គបណ្តុះបណ្តាលស្តីពី«ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០»*

## ២.៧. កិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត

### ២.៧.១ កម្មវិធីសម្ពោធកិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត




*រូបភាពទី 10៖ កម្មវិធីសម្ពោធកិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត*

ដើម្បីបង្កើនប្រសិទ្ធភាពនៃការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាក្នុងវិស័យទឹកស្អាត ជាពិសេសក្នុងចំណោមសមាជិក សមាគមបានបង្កើតកម្មវិធីកិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត។

កម្មវិធីនេះត្រូវបានសម្ពោធចាប់ផ្តើមនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ (Zoom) ដោយទទួលបានការចូលរួមពីក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងសមាជិកចំនួនប្រមាណ ៣០ នាក់។

ក្នុងកម្មវិធីនេះ លោកនាយកប្រតិបត្តិបានបញ្ជាក់ជូនអ្នកចូលរួមថា កិច្ចសន្ទនានេះបើកជាសាធារណៈ ហើយសមាជិកអាចផ្ញើប្រធានបទមកសមាគមដើម្បីរៀបចំ និងស្វែងរកវាគ្មិនដែលមានចំណេះដឹង និងបទពិសោធន៍ល្អៗមកចូលរួមចែករំលែក។

### ២.៧.២ កិច្ចសន្ទនាប្រចាំខែលើប្រធានបទ«ស្តីពីរបៀបលាងបណ្តាញបំពង់ទឹកស្អាត»

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ សមាគមបានរៀបចំកិច្ចសន្ទនាប្រចាំខែលើកទី១ តាមប្រព័ន្ធអនឡាញ (Webinar) «ស្តីពីរបៀបលាងបណ្តាញបំពង់ទឹកស្អាត»។

កិច្ចសន្ទានេះមានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសដោយ **លោក លឹម មិញ** នាយកប្រតិបត្តិ និង **លោក ជ្រិន ផាត់** វិស្វករជំនាញជាន់ខ្ពស់ទឹកស្អាត។ កិច្ចសន្ទនានេះទទួលបានអ្នកចូលរួមសរុបប្រមាណជា ២៥ នាក់។ សមាគមក៏បានផ្សាយផ្ទាល់កម្មវិធីនេះនៅលើទំព័រហ្វេសប៊ុកផងដែរ ដែលមានអ្នកចូលមើលចំនួនប្រមាណជា២០០០ និងចូលរួមចំនួន៩៣។




*រូបភាពទី 11៖ កិច្ចសន្ទនាអំពី របៀបលាងបណ្តាញបំពង់ទឹកស្អាត*

## ៣. កិច្ចសហប្រតិបត្តិការ

### ៣.១. ការរៀបចំសិក្ខាសាលាទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន

ថ្ងៃទី១៤-១៥ ខែមករា ឆ្នាំ២០២៦ សមាគម CWA បានសហការជាមួយក្រសួង MISTI ក្រសួងសាធារណការ និង ដឹកជញ្ជូន (MPWT) ក្រសួងរៀបចំដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ (MLIT) ការិយាល័យទឹកស្អាត និងប្រព័ន្ធអនាម័យ ទីក្រុងឃីតាឃ្យូស៊ុ សមាគមអាជីវកម្មទឹកក្រៅប្រទេស ទីក្រុងឃីតាឃ្យូស៊ុ (KOWBA) រៀបចំសិក្ខាសាលាស្តីពី«**ទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន លើកទី១៨**» នៅសណ្ឋាគារ សាន់ អ៊ែន មូន រីវើសាយ ក្រោមការគាំទ្រពី ស្ថានទូតជប៉ុន/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។

សិក្ខាសាលាប្រព្រឹត្តិទៅក្រោមអធិបតីភាព **ឯកឧត្តម ស៊ីម ស៊ីថា** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. **ឯកឧត្តម អ៊ុអឺណុ អាត់ស៊ុស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម រស់ វណ្ណា** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន។




*រូបភាពទី 12៖ សិក្ខាសាលាស្តីពី«ទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន លើកទី១៨»*

ទន្ទឹមនឹងនេះដែរក៏មានការអញ្ជើញចូលរួមពី គណៈប្រតិភូជប៉ុន តំណាងមកពីក្រសួង ឧ.វ.ប.ន. តំណាងមកពីក្រសួងសាធារណការ និងដឹកជញ្ជូន តំណាងមកពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និង សៀមរាប រដ្ឋាករទឹកកំពង់ចាម កំពត កំពង់ធំ តាំងក្រសាំង-ស្ទោង បាត់ដំបង ពោធិ៍សាត់ ស្វាយរៀង ស្ទឹងត្រែង និង មណ្ឌលគិរី និងតំណាងមកពីមន្ទីរ ឧ.វ.ប.ន. និងមន្ទីរសាធារណការ និងដឹកជញ្ជូន ទូទាំង ២៥ រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ស្ថានទូតជប៉ុន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន សមាគម KOWBA សមាគម CWA និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនប្រមាណ ៦០ ស្ថានីយ។ ក្នុងនោះផងដែរសមាគមក៏បានសម្របសម្រួលទស្សនកិច្ចសិក្សាជូនប្រតិភូជប៉ុន ដែលជាពាណិជ្ជករពាក់ព័ន្ធនឹងវិស័យទឹកស្អាតប្រមាណ ៤០ នាក់ ទៅកាន់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតថ្នល់ទទឹង ដើម្បីស្វែងយល់អំពីការផលិត និងផ្គត់ផ្គង់ទឹកស្អាតនៅព្រះរាជាណាចក្រកម្ពុជា។

## ៣.២. ការសហការជាមួយ Impact Investment Exchange

ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ សមាគមបានសហការជាមួយ Impact Investment Exchange (IIX) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងការរៀបចំសិក្ខាសាលាអនឡាញ (Zoom)ស្តីពី «**ការដាក់ឱ្យដំណើរការកម្មវិធី Climate Venture Scaler (CVS)**» ដែលជាគំនិតផ្តួចផ្តើមថ្នាក់តំបន់។ កម្មវិធីនេះរៀបចំឡើងដើម្បីជួយបង្កើនសមត្ថភាពសហគ្រាសដោះស្រាយបញ្ហាអាកាសធាតុដែលស្ថិតក្នុងដំណាក់កាលលូតលាស់នៅក្នុងប្រទេសឡាវ ម៉ាឡេស៊ី និងកម្ពុជា ក្នុងការពង្រីកឥទ្ធិពលរបស់ខ្លួន ពង្រឹងការត្រៀមលក្ខណៈវិនិយោគ និងភ្ជាប់ទំនាក់ទំនងជាមួយវិនិយោគិនអន្តរជាតិ។ សិក្ខាសាលានេះមានអ្នកចូលរួមសរុបចំនួន ៤១ នាក់។



*រូបភាពទី 13៖ សិក្ខាសាលាអនឡាញស្តីពី «ការដាក់ឲ្យដំណើរការកម្មវិធី Climate Venture Scaler (CVS)»*

## ៣.៣. ចូលរួមក្នុងសន្និបាតក្រសួង ឧ.វ.ប.ន.

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ សមាគមបានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួង ឧ.វ.ប.ន. នៅសណ្ឋាគារ សុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧ.វ.ប.ន.។



*រូបភាពទី 14៖ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រសួង ឧ.វ.ប.ន.*

## ៣.៤. សន្និសីទទឹកប្រទេសហ្វីលីពីន

ថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០២៦ នាយកប្រតិបត្តិសមាគមបានចូលរួមក្នុងកម្មវិធីអនុសញ្ញាទឹកលើកទី **៤៧** របស់សមាគមទឹកហ្វីលីពីន ថ្នាក់ស្រុក ដែលរៀបចំនៅទីក្រុងម៉ានីល ប្រទេសហ្វីពីន។ នៅរសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២៦ លោកនាយកប្រតិបត្តិបានចូលរួមចែករំលែកអំពីបញ្ហាប្រឈម ដំណោះស្រាយ និងឱកាសវិនិយោគលើវិស័យ ទឹកស្អាតនៅកម្ពុជា។




*រូបភាពទី 15៖ កម្មវិធីអនុសញ្ញាទឹកលើកទី៤៧ របស់សមាគមទឹកហ្វីលីពីន*

## ៣.៥. សន្និសីទទឹកប្រទេសកូរ៉េ

ថ្ងៃទី១៧-២១ ខែមីនា ឆ្នាំ២០២៦ នាយកប្រតិបត្តិសមាគមបានចូលរួម សន្និសីទទឹកកូរ៉េ ២០២៦ (Korean Water 2026) នៅទីក្រុងប៊ូសាន់ (Buson, South of Korea)។ ក្នុងនោះនាយកប្រតិបត្តិសមាគម និង លោក សៀ សេងហ៊ាប ម្ចាស់ស្ថានីយទឹកស្អាតបែកចាន បានជួបប្រជុំជាមួយ លោកអគ្គនាយកប្រតិបត្តិ AMO Green Tech ដើម្បីបង្កើនទំនាកទំនង និងកិច្ចសហការក្នុងការអនុវត្តសាកល្បងនូវបច្ចេកវិទ្យាបន្ទុទ្ធរបស់ AMO Green Tech នៅស្ថានីយទឹកស្អាតបែកចាន។ ជាងនេះទៅទៀត លោកនាយកប្រតិបត្តិ និងលោក សៀ សេងហ៊ាប បានចូលរួមប្រជុំជាមួយក្រុមហ៊ុនបច្ចេកវិទ្យាកូរ៉េផងដែរ និងចែករំលែកពីតម្រូវការបច្ចេកវិទ្យាសម្រាប់វិស័យទឹកស្អាតនៅកម្ពុជា។




*រូបភាពទី 16៖ កិច្ចប្រជុំជាមួយលោកអគ្គនាយកក្រុមហ៊ុន AMO Green Tech និង សន្និសិទទឹកកូរ៉េ ២០២៦*

# ៤. ការងារគម្រោង

## ៤.១ គម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

### ៤.១.១ ការជ្រើសរើសសមាជិកគម្រោងបន្ថែម

ក្នុងត្រីមាសទី១ ឆ្នាំ២០២៦ នេះ គម្រោងបានជ្រើសរើសសមាជិកបន្ថែមចំនួន ៩ **ស្ថានីយ**។ សមាជិកគម្រោងសរុបគឺ ៥៨ ស្ថានីយ។

| ល.រ | ឈ្មោះស្ថានីយ | ឈ្មោះប្រតបត្តិករ | ទីតាំង |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ថ្នល់ទទឹង | លោកស្រី សុខ ហៀង | ខេត្តកណ្តាល |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកតាមាក់ | លោកស្រី គ្រី កៅនី | ខេត្តកណ្តាល |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពាម | លោក លឹម គឹមហេង | ខេត្តកំពង់ឆ្នាំង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រតនមង្គល | លោក ណុប ប៊ិន | ខេត្តបាត់ដំបង |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំពៅលូន | លោក ជា សុខន | ខេត្តបាត់ដំបង |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អង្គរអង្គ | លោក ជា សារិទ្ធ | ខេត្តព្រៃវែង |
| ៧ | ស្ថានីយទឹកស្អាត ឃុំបន្ទាយចក្រី | លោកស្រី សន សុខា | ខេត្តព្រៃវែង |
| ៨ | ទឹកស្អាតភូមិបាណន់ | លោក ប៊ឹង លួម | ខេត្តបាត់ដំបង |
| ៩ | ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត | លោក ខោ ប៊ុនហ៊ាត | ខេត្តបាត់ដំបង |

### ៤.១.២ ការកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ

#### ក. ការគាំទ្រប្រតិបត្តិករលើផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

ក្រុមការងារសមាគមបានបន្តធ្វើការជាមួយក្រុមហ៊ុនបញ្ចី ដើម្បីចូលរួមគាំទ្រ និងតាមដានអំពីភាពរីកចម្រើននៃការប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ចី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតបានចំនួន ៩ **ស្ថានីយ**។

#### ខ. ការពង្រឹងសមត្ថភាពប្រតិបត្តិករដើម្បីមានលទ្ធភាពទទួលបានឥណទាន និងការទូទាត់សង

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការពង្រឹងសមត្ថភាពប្រតិបត្តិករដើម្បីបង្កើនលទ្ធភាពទទួលបានឥណទាន និងសមត្ថភាពទូទាត់សង**» ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងមន្ត្រីធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា (SME Bank)។ ជាលទ្ធផលមានអ្នកចូលរួមសរុបចំនួន ៥៤ នាក់ (ស្រី ៧ នាក់) ក្នុងនោះមានសមាសភាពអញ្ជើញមកពីក្រសួង ឧ.វ.ប.ន. ១ នាក់ (ប្រុស ១ នាក់) ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ៣៨ នាក់ (ស្រី ៤ នាក់) មកពី ៣៧ ស្ថានីយ បុគ្គលិកធនាគារ SME Bank ១០ នាក់ (ស្រី ១ នាក់) អង្គការ Water.org ២ នាក់(ប្រុស ២នាក់) និងសមាគម ៣ នាក់ (ស្រី ២ នាក់)។



*រូបភាពទី 17៖ កម្មវិធីបើកវគ្គបណ្តុះបណ្តាល*

### ៤.១.២ ដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី

សមាគមបានអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ពីក្រសួង ឧ.វ.ប.ន. ចំនួន ៤ នាក់ និងបានជ្រើសរើសប្រតិបត្តិករចំនួន ១២ ស្ថានីយ ដើម្បីចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី សម្រាប់រយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦។ ដំណើរទស្សនកិច្ចសិក្សានេះ មានគោលបំណងសិក្សាស្វែងយល់អំពីការគ្រប់គ្រងទឹកស្អាត បទប្បញ្ញត្តិបច្ចេកទេស និងមេរៀនបទពិសោធន៍ពីការអនុវត្តល្អក្នុងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅប្រទេសឥណ្ឌូនេស៊ី ព្រមទាំងស្វែងយល់អំពីវិធីសាស្ត្រកៀរគរមូលនិធិការវិនិយោគ និងហិរញ្ញប្បទានជួយវិស័យទឹកស្អាត ជាពិសេសការពង្រឹង និងគាំទ្រប្រតិបត្តិករទឹកស្អាតឯកជន។

### ៤.១.៣ ការគាំទ្រដល់សមាជិកគម្រោង

#### ក. ការប្រមូល និងផ្តល់អនុសាសន៍ លើលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ៥ប៉ារ៉ាម៉ែត្រ

សមាគមបានប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ រៀងរាល់ខែពីសមាជិក **៥៨ ស្ថានីយ** ក្នុងនោះ **៥៤ ស្ថានីយ**បានផ្ញើលទ្ធផលតេស្តមកសមាគមជាទៀងទាត់។ សមាគមបានផ្តល់ជាការណែនាំដល់ប្រតិបត្តិករក្នុងករណីលទ្ធផលមិនអនុលោមតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ។

#### ខ. ការគាំទ្រលើការតាមដានទឹកគ្មានចំណូល

សមាគមបានប្រមូលលទ្ធផលតាមដានទឹកគ្មានចំណូលក្នុងខែមករា និងខែកុម្ភៈ ពីសមាជិកគម្រោងចំនួន ៦៤ ស្ថានីយ ក្នុងនោះ ៤៣ ស្ថានីយបានផ្ញើលទ្ធផលមកសមាគម។ ជាលទ្ធផលបានបង្ហាញថា៖

- ➢កម្រិត ល្អ / ប្រសិទ្ធភាព ( NRW < 20% )៖ ២៧ ស្ថានីយ
- ➢កម្រិត មធ្យម / អាចទទួលយកបាន ( NRW 20%–30%)៖ ១១ ស្ថានីយ
- ➢កម្រិត ទាប/ ការបាត់បង់ខ្ពស់ ( NRW> 30%)៖ ៥ ស្ថានីយ

### គ. ការផ្តល់សេវាគូរផែនទីបណ្តាញ និងការរៀបចំផែនការវិនិយោគរយៈពេលមធ្យម

សមាគមបានផ្តល់សេវាកម្មជូនសមាជិក៖ សេវាកម្មនេះត្រូវបានចូលរួមបដិភាគពីអង្គការ Water.org ប្រតិបត្តិករ និងសមាគម៖

១. គូរផែនទីបណ្តាញបំពង់ទឹកស្អាត បានចំនួន ១ ស្ថានីយ
២. រៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០ បានចំនួន ៣ ស្ថានីយ
៣. គូរផែនទីបណ្តាញបំពង់ទឹកស្អាត និងផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០ បានចំនួន ៨ ស្ថានីយ។
៤. កំពុងរៀបចំកិច្ចព្រមព្រៀងផ្តល់សេវាទាំងពីរ ជូនសមាជិកចំនួន ៨ ស្ថានីយបន្ថែមទៀត។




*រូបភាពទី 18៖ បុគ្គលិកសមាគមចុះផ្តល់សេវាកម្មជូនសមាជិក*

### ឃ. ឧបត្ថម្ភដល់សមាជិកគម្រោងចូលរួមក្នុងវគ្គបណ្តុះបណ្តាល

សមាជិកគម្រោងសរុបចំនួន ១១ ស្ថានីយ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី«ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០»។ ជាលទ្ធផល ៥ ស្ថានីយ បានបញ្ចប់ការរៀបចំផែនការ និងដាក់ជូនក្រសួង ឧ.វ.ប.ន.។

## ៤.១.៤ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

### ក. ការសម្របសម្រួលកម្ចី

❖ សម្របសម្រួល និងតាមដានសមាជិកចំនួន **១២ ស្ថានីយ** ស្នើប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ។ ជាលទ្ធផល **៦ ស្ថានីយ** ទទួលបានប្រាក់កម្ចីពីធនាគារ **១.២៣៦.៥០០ ដុល្លារអាមេរិក** (**៥៩៥.២៩២ ដុល្លារអាមេរិក** ប្រើប្រាស់ដើម្បីសងត្រលប់កម្ចី និង **៦៤១.២០៨ ដុល្លារអាមេរិក** ប្រើប្រាស់សម្រាប់អភិវឌ្ឍអាជីវកម្មទឹកស្អាតដូចជា៖ ដំឡើងប្រព័ន្ធសូឡា សាងសង់អាងប្រព្រឹត្តកម្មថ្មី ប្តូរប្រព័ន្ធម៉ូទ័របញ្ជាទឹកផៅ ផ្លាស់ប្តូរ

ប្រព័ន្ធចាក់បញ្ចូលសារធាតុគីមី ដំឡើងម៉ូទ័របញ្ចាញទឹកស្អាត និងទូរបញ្ជា ដំឡើងដំបូលអាងទឹកស្អាត កែលម្អអាងប្រព្រឹត្តកម្មចាស់ ដំឡើងម៉ូទ័រខ្យល់លាងខ្សាច់ ខួងបេតុងដាក់ប្រព័ន្ធម៉ូទ័របូមទឹកស្អាត និងពង្រីកបណ្តាញបំពង់ទឹកស្អាត)។ ស្ថានីយទាំង ៦ ខាងលើមានកំណើនតំណអតិថិជនថ្មីចំនួន **១.៣៧៨ តំណ** ស្មើនឹងប្រជាជនចំនួន **៦.៧៥២** នាក់ទទួលបានសេវាទឹកស្អាតប្រើប្រាស់។

- ត្រឹមឆ្នាំ២០២៥ សមាជិកចំនួន **៥៣ ស្ថានីយ** មានតំណ 139,030 vs ត្រឹមខែមីនា ឆ្នាំ២០២៦ មានតំណ 141,975 (កើន 2,945 តំណ ស្មើនឹង 14,431 នាក់)។

## ៤.១.៤ កិច្ចប្រជុំរបស់គម្រោង

នៅក្នុងត្រីមាសទី១ គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយប្រតិបត្តិករនៅខេត្តបាត់ដំបង និងពោធិ៍សាត់។ ជាលទ្ធផល ប្រតិបត្តិករចំនួន ១១ ស្ថានីយ បានចូលរួមក្នុងកិច្ចប្រជុំ និងមានប្រតិបត្តិករចំនួន ៤ ស្ថានីយ មកពីខេត្តបាត់ដំបងបានចូលរួមចុះឈ្មោះចូលគម្រោង។

១. ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងធនាគារ FTB មានអ្នកចូលរួមសរុប ៥ នាក់ (ស្រី ២ នាក់)។ កិច្ចប្រជុំមានគោលបំណងពិភាក្សាអំពីការកសាងសមត្ថភាពជូនដល់ប្រតិបត្តិករដែលជាអតិថិជនរបស់ធនាគារ FTB។

២. ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងធនាគារ SME Bank មានអ្នកចូលរួមសរុប ៤ នាក់ (ស្រី ២ នាក់)។ កិច្ចប្រជុំមានគោលបំណងពិភាក្សាអំពីការរៀបចំវគ្គបណ្តុះបណ្តាលជូនដល់ប្រតិបត្តិករដែលជាអតិថិជន និងបុគ្គលិករបស់ធនាគារ SME Bank ។

៣. ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦៖ កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ជាមួយអគ្គនាយកដ្ឋានទឹកស្អាត និងអង្គការ Water.org នៅសណ្ឋាគារ សាន់វេ ភ្នំពេញ មានអ្នកចូលរួមសរុប ៩ នាក់ (ស្រី ៤ នាក់)។ កិច្ចប្រជុំមានគោលបំណងពិនិត្យមើលលើវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ បញ្ហាប្រឈម ដំណោះស្រាយ និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦ និងត្រីមាសបន្ទាប់។



*រូបភាពទី 19៖ កិច្ចប្រជុំប្រចាំត្រីមាសទី១*

### ៤.១.៥ ការគាំទ្រសកម្មភាពស្នូលរបស់សមាគម

នៅក្នុងត្រីមាសទី១ គម្រោងបានគាំទ្រការងារស្នូលរបស់សមាគម ដូចខាងក្រោម៖

១. បោះពុម្ពឡើងវិញសៀវភៅ«ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត»ចំនួន **៥.០០០ ក្បាល** និងបានចែកជូនក្រសួង ឧ.វ.ប.ន. ប្រតិបត្តិករ និងអ្នកពាក់ព័ន្ធសរុបចំនួន **២.៤៥៣ ក្បាល**។

២. គាំទ្រដល់សន្និបាតលើកទី១៤ ឆ្នាំ២០២៦ ដែលប្រារព្ធនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ នៅភោជនីយដ្ឋានទន្លេបាសាក់២ មានអ្នកចូលរួមសរុបចំនួន **៤១២ នាក់** (ស្រី ១២៣ នាក់) រួមទាំងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ២៣០ នាក់ មកពី ១៦៩ ស្ថានីយ។